Australian Government

NATIONAL BOWELCANCER SCREENING PROGRAM

# ការណែនាំអំពីកញ្ចប់ធ្វើតេស្តនៅផ្ទះ

**ប្រមូលសំណាកតូចចំនួន 2 រួចដាក់វានៅក្នុងប៉ុស្តិ៍ប្រៃសណីយ៍ ហើយអ្នកបានធ្វើវារួចរាល់ហើយ។**

## សំខាន់

- បញ្ចប់ការធ្វើតេស្តនោះនៅក្នុងរយៈពេល 2 សប្តាហ៍ខាងមុខ។
- ដាក់បញ្ចូលទម្រង់បែបបទរបស់ទៅក្នុងស្រោមសំបុត្រនោះ នៅពេលអ្នកបញ្ជូនសំណាករបស់អ្នកត្រឡប់ទៅវិញ។

## កញ្ចប់របស់អ្នកមានគ្រប់អ្វីៗដែលអ្នកត្រូវការសម្រាប់ធ្វើតេស្ត




ទម្រង់បែបបទ x 1 សម្រាប់ព័ត៌មានលម្អិតនៃអ្នកចូលរួម



បំពង់ប្រមូលចំនួន x 2




ទ្រនាប់បង្គន់ចំនួន x 2



ថង់មានខ្សែរូតកិប x 1



ស្រោមសំបុត្រឆ្លើយដែលបានបង់ប្រាក់ស្រេចចំនួន x 1

## នៅមុនពេលអ្នកធ្វើតេស្ត

- ✓ ដាក់កញ្ចប់ធ្វើតេស្តនៅជិតបង្គន់ ជាកន្លែងដែលអ្នកនឹងចងចាំក្នុងការធ្វើតេស្ត។
- ✓ កំណត់ការរម្លឹកអំពីថ្ងៃដែលអ្នកត្រូវយកសំណាករបស់អ្នក។
- ✓ ពិនិត្យមើលកាលបរិច្ឆេទផុតកំណត់ដែលមាននៅខាងខ្នងកញ្ចប់។ ប្រសិនបើកញ្ចប់បានផុតកំណត់ហើយ សូមហៅទូរសព្ទទៅ 1800 627 701 ដើម្បីទទួលបានកញ្ចប់ជំនួសវិញ។
- ✓ សូមបន្តពិសាឱសថដែលអ្នកមាន និងបរិភោគអ្វីដែលអ្នកបរិភាគជាធម្មតា។

## កុំធ្វើតេស្ត ប្រសិនបើអ្នកមាន៖

- ✗ ឫសដូងបាត ដែលកំពុងហូរឈាម។ ប្រសិនបើរឿងនេះកើតឡើង សូមទៅជួបវេជ្ជបណ្ឌិតរបស់អ្នក
- ✗ ឈាមនៅក្នុងទឹកនោមរបស់អ្នក ឬឈាមនៅក្នុងចានបង្គន់។ ប្រសិនបើរឿងនេះកើតឡើង សូមជួយវេជ្ជបណ្ឌិតរបស់អ្នក
- ✗ រយៈពេលមករដូវរបស់អ្នក។ ធ្វើតេស្ត 3 ថ្ងៃ ក្រោយរយៈពេលមករដូវរបស់អ្នកបានចប់
- ✗ ទើបនឹងបានធ្វើការឆ្លុះមើលផ្នែកខាងក្នុងនៃពោះវៀនធំថ្មីៗនេះ។

## លទ្ធផលរបស់អ្នក

លទ្ធផលរបស់អ្នកនឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ទៅឱ្យអ្នក និងវេជ្ជបណ្ឌិតរបស់អ្នកនៅក្នុងរយៈពេល 4 សប្តាហ៍ ក្រោយអ្នកផ្ញើសំណាករបស់អ្នកតាមប្រៃសណីយ៍។

លទ្ធផល **អវិជ្ជមាន** មានន័យថាមិនឃើញមានឈាមទេ។ អ្នកគួរធ្វើតេស្តម្តងទៀតក្នុងរយៈពេល 2 ឆ្នាំទៀត។

លទ្ធផល **វិជ្ជមាន** មានន័យថាបានរកឃើញឈាម។ នេះមិនមែនមានន័យជានិច្ចថាអ្នកមានជំងឺមហារីកពោះវៀននោះទេ។ មានហេតុផលជាច្រើនដែលអ្នកអាចមានឈាមនៅក្នុងលាមករបស់អ្នក ហើយភាគច្រើនមិនទាក់ទងនឹងជំងឺមហារីកទេ។ ធ្វើការណាត់ពេលជួបវេជ្ជបណ្ឌិតរបស់អ្នកឱ្យបានលឿនដែលអាចធ្វើទៅបាន ដើម្បីស្វែងយល់បន្ថែមទៀត។

មើលវីដេអូស្តីពីរបៀបធ្វើតេស្ត
**www.health.gov.au/nbcsp**



Bowel-Test-Kit-Instructions_Khmer

# ការណែនាំ

## 1 រៀបចំ



**សរសេរ ឈ្មោះ** ថ្ងៃខែឆ្នាំកំណើតរបស់អ្នក និងកាលបរិច្ឆេទដែលអ្នកធ្វើតេស្តនៅលើបំពង់មួយក្នុងចំណោមបំពង់នានា។




បត់ជើងតូច ហើយ**ចុចចាក់ទឹក**បង្គន់ចោល។

**ដាក់ទ្រនាប់បង្គន់មួយចូលទៅក្នុងបង្គន់** ដោយដាក់ខាងមានអក្សរបែរឡើងលើ។ វាមិនអីទេ ប្រសិនបើទ្រនាប់នោះសើម។

## 2 ប្រមូល



**ជុះ** លើទ្រនាប់នោះ។



**មួលបើកបំពង់**។ អូសចុងចង្កឹះឈើឆ្លងកាត់លាមក។ សំណាករបស់អ្នកត្រូវការតែលាមកបន្តិចប៉ុណ្ណោះ។

ដាក់ចង្កឹះឈើនោះចូលទៅក្នុងបំពង់វិញ និងចុចបិទវា។ **ចុចចាក់ទឹក**នាំទ្រនាប់ដែលនឹងរលាយចោល។



**ដាក់បំពង់ចូលទៅក្នុងថង់មានខ្សែរូតកិប។**

ដាក់ទុកថង់នៅកន្លែងណាមួយដែលត្រជាក់ ដូចជាទូរទឹកកក។ កុំបង្កកវា។

## 3 ធ្វើដដែលឡើងវិញ



**ធ្វើជំហានទី 1 និងទី 2 ឡើងវិញ**ដោយប្រើបំពង់មួយទៀត នៅពេលអ្នកជុះបញ្ចេញលាមកនៅលើកបន្ទាប់ទៀត។ ជាការល្អ ព្យាយាមប្រមូលសំណាកទាំងពីរនៅក្នុងរយៈពេល 3 ថ្ងៃពីគ្នា។

បន្ទាប់មកទៅកាន់ជំហានទី 4។

## 4 ផ្ញើ

### ផ្ញើសំណាករបស់អ្នកតាមប្រៃសណីយ៍ឱ្យបានលឿនដែលអាចធ្វើទៅបាន។




**បំពេញទម្រង់បែបបទព័ត៌មានលម្អិតរបស់អ្នកចូលរួម។** សរសេរកាលបរិច្ឆេទដែលអ្នកបានយកសំណាកនីមួយៗ និងចុះហត្ថលេខាលើទម្រង់បែបបទនោះ។



**នៅលើស្រោមសំបុត្រ** ចុះហត្ថលេខាលើផ្នែកខាងមុខ និងសរសេរឈ្មោះនិងអាសយដ្ឋានរបស់អ្នកនៅផ្នែកខាងខ្នង។

**ដាក់ទម្រង់បែបបទនិងសំណាក**ចូលទៅក្នុងស្រោមសំបុត្រ។



**ផ្ញើស្រោមសំបុត្រតាមប្រៃសណីយ៍។** សំណាកត្រូវការនៅត្រជាក់ឱ្យបានយូរដែលអាចធ្វើទៅបាន។ ដាក់វានៅក្នុងប្រអប់ផ្ញើសំបុត្រនៅថ្ងៃណាដែលត្រជាក់ ឬយកវាទៅការិយាល័យប្រៃសណីយ៍។

## សំណួរនានា

**ខ្សែទូរសព្ទជំនួយអំពីកញ្ចប់ធ្វើតេស្ត៖**
1800 930 998។

**បញ្ជីការក្នុងការធ្វើតេស្តរកមើលជំងឺមហារីកថ្នាក់ជាតិ (National Cancer Screening Register)៖**
1800 627 701។

**ចូលមើលគេហទំព័ររបស់យើង៖**
www.health.gov.au/nbcsp។

## ការបកប្រែ

Interpreter

**សម្រាប់ព័ត៌មានជាភាសារបស់អ្នក**
www.health.gov.au/nbcsp-translations។

**ភាសា និងសេវាបកប្រែ៖** 13 14 50។

PATHOLOGY SERVICES

SONIC HEALTHCARE

SPONSOR

r-biopharm

MANUFACTURER

EIKEN CHEMICAL CO., LTD.